ឡជីវឧស្ម័នធ្វើឲ្យជីវភាពប្រជាជនក្នុងខេត្តស្វាយរៀងប្រសើរឡើង

នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ ប្រតិភូ CCCA រួមមានបុគ្គលិក CCCA និងតំណាងពីដៃគូអភិវឌ្ឍន៍ ដូចជា សហភាពអឺរ៉ុប UNDP និងស្ថានទូត ស៊ុយអែដ បានជួបសំណេះសំណាលជាមួយអ្នកទទួលផលពីគម្រោងរបស់CCCA នៅខេត្តស្វាយរៀង។

"អ្នកស្រី អ៊ិន សុខ អាយុ ៥៤ ឆ្នាំ នៅភូមិអង្គក្លូច ស្រុកចន្ទ្រា បាននិយាយថា "កាលពីមុនខ្ញុំត្រូវកាប់អុសពីព្រៃ និងមានភាពនឿយហត់ខ្លាំងជារៀងរាល់ថ្ងៃ។ នៅពេលមានឡជីវឧស្ម័ន សុខភាពរបស់ខ្ញុំប្រសើរជាងមុន ហើយខ្ញុំអាចចាត់ចែងម្ហូបអាហារសម្រាប់គ្រួសារបានល្អជាងមុន តាមរយៈការដាំបន្លែដោយប្រើសំណល់ពីឡជីវឧស្ម័ន។

អ្នកស្រី អ៊ិន សុខ និងចង្ក្រានជីវឧស្ម័នរបស់គាត់

គម្រោង"ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈមុខរបរគួបផ្សំនៅក្នុងសហគមន៍ព្រៃឈើ" (Adaptation to Climate Change through Alternative Livelihoods in Community Forestry) ដែលអនុវត្តដោយនាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ កំពុងជួយដល់សហគមន៍ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការកែប្រែទម្លាប់ក្នុងការចិញ្ចឹមជីវិត។ សកម្មភាពគម្រោងរួមមានការកសាងសមត្ថភាពសហគមន៍ ដើម្បីគ្រប់គ្រងសហគមន៍ព្រៃឈើប្រកបដោយនិរន្តរភាព និងផ្តល់ជម្រើសសម្រាប់សកម្មភាពបន្សាំដើម្បីពង្រឹងសន្តិសុខស្បៀងតាមរយៈការធ្វើសួនបន្លែ និងឡជីវឧស្ម័ន។ ស្ត្រីជាអ្នកដែលទទួលបានអត្ថប្រយោជន៍ច្រើនពីគម្រោងនេះ។ ការងារផ្ទះរបស់ពួកគេត្រូវបានកាត់បន្ថយ ហើយពួកគេអាចធានាបានសន្តិសុខស្បៀងសម្រាប់គ្រួសាររបស់ពួកគេដោយប្រើប្រាស់ឡជីវឧស្ម័ន និងបច្ចេកទេសដាំបន្លែនៅតាមផ្ទះ។

លាមកសត្វត្រូវបានប្រមូលទុកសម្រាប់ផលិតជាឧស្ម័នមេតាន ដែលអាចយកទៅដុតទាញយកថាមពលសម្រាប់ចំអិនអាហារ និងបំភ្លឺ។ ការធ្វើបែបនេះអាចកាត់បន្ថយការពឹងផ្អែកលើការប្រើប្រាស់អុស និងអគ្គិសនីដែលមានតម្លៃខ្ពស់។ សំណល់ពីឡជីវឧស្ម័នអាចយកទៅប្រើប្រាស់ជាជីសរីរាង្គ ដើម្បីជំនួសជីគីមី និងផ្តល់ជាចំណីដល់សត្វ និងត្រី។ ប្រជាជនអាចសន្សំប្រាក់ និងទទួលបានចំណូលពីសួនបន្លែ និងការចិញ្ចឹមសត្វ។

សួនបន្លែដែលមានដំណាំត្រសក់ និងត្រកួន ដោយប្រើប្រាស់សំណល់ពីឡជីវឧស្ម័ន

គម្រោងនេះក៏ធ្វើការផងដែរលើការកសាងសមត្ថភាពសហគមន៍ ដើម្បីថែរក្សាព្រៃឈើសហគមន៍ លើផ្ទៃដី ៤០៤ ហិកតា។ បច្ចុប្បន្ននេះ ប្រជាជន ៦៧៧ គ្រួសារក្នុងស្រុកចំនួនបី បានក្លាយជាសមាជិកសហគមន៍ព្រៃឈើ ហើយពួកគេបានស្ម័គ្រចិត្តការពារព្រៃនេះ។ ប្រជាជនអាចទទួលបានផលខ្លះៗ ដោយផ្ទាល់ ពីព្រៃនេះ រួមមានការប្រមូលផ្សិតព្រៃ ឱសថបុរាណ និងមែកឈើងាប់សម្រាប់យកធ្វើជាអុស។

ព្រឹត្តិការណ៍នៅពេលខាងមុខ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ៖

- កិច្ចប្រជុំពិគ្រោះយោបល់អំពី CCCSP ជាមួយក្រសួងពាក់ព័ន្ធចំនួនប្រាំបួនថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៣ នៅខេត្តព្រះសីហនុ។
- កិច្ចប្រជុំស្តីពីទំនាក់ទំនងក្នុងការងារប្រែប្រួលអាកាសធាតុ ខែឧសភា ឆ្នាំ ២០១៣ នៅរាជធានីភ្នំពេញ។
- ទិវាបរិស្ថានជាតិ និងពិភពលោក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ នៅរាជធានីភ្នំពេញ។
- សិក្ខាសាលាថ្នាក់ខេត្តស្តីពីការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ថ្ងៃទី ២០-២១ ខែមិថុនា ឆ្នាំ ២០១៣ នៅខេត្តសៀមរាប។
- សម័យប្រជុំលើកទីពីរ នៃក្រុមការងារបណ្តោះអាសន្នស្តីពីវេទិកាឌូបានសម្រាប់ពង្រឹងចំណាត់ការ (ADP2), ថ្ងៃទី ២៩ ខែមេសា-ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ នៅទីក្រុងបោន ប្រទេស អាល្លឺម៉ង់។
- សម័យប្រជុំលើកទី ៣៨ នៃអង្គភាពអនុវត្ត (SBI38) និងអង្គភាពផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកទេស (SBSTA38) និងសម័យប្រជុំលើកទីបី នៃក្រុមការងារបណ្តោះអាសន្នស្តីពីវេទិកាឌូបានសម្រាប់ពង្រឹងចំណាត់ការ (ADP3), ខែឧសភា ឆ្នាំ ២០១៣ នៅទីក្រុងបោន ប្រទេសអាល្លឺម៉ង់។

ព្រឹត្តិបត្រព័ត៌មាន CCCA ផ្តល់ព័ត៌មានអំពីសកម្មភាពរបស់កម្មវិធី CCCA ព័ត៌មានដែលទាក់ទងនឹងគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ និងលទ្ធផលការងារសម្រេចបានដោយគម្រោងនៅតាមសហគមន៍ក្រោមជំនួយរបស់ CCCA ។ ទស្សនៈដែលបានបញ្ចេញក្នុងព្រឹត្តិបត្រព័ត៌មាននេះ មិនតំណាងឲ្យទស្សនៈរបស់ក្រសួងបរិស្ថាន សហភាពអឺរ៉ុប UNDP Sida និង Danida ទេ។

អត្ថបទក្នុងលេខនេះមាននៅក្នុងគេហទំព័រ
www.camclimate.org.kh

ដើម្បីទទួលព្រឹត្តិព័ត៌មាន CCCA ជាទម្រង់អេឡិចត្រូនិក
សូមទាក់ទងមក: contactcamclimate@gmail.com

ជំហររបស់កម្ពុជា ក្នុងសន្និសីទ COP18, និងការឆ្លើយតបជាអន្តរជាតិ

អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បានរៀបចំសន្និសីទលើកទី ១៨ (CoP 18)ចាប់ពីថ្ងៃទី២៦ ខែវិច្ឆិកា ដល់ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ ២០១២ នៅទីក្រុងដូហា ប្រទេសកាតា។ សន្និសីទនេះមានការចូលរួមពីតំណាងចំនួន ៩.០០០ នាក់ មកពីប្រទេសចំនួន ១៩២។ ប្រតិភូប្រទេសកម្ពុជា ដែលមានសមាជិកចំនួន ២៣ នាក់ និងដឹកនាំដោយ ឯកឧត្តម ធឹក គ្រឿនវុត្ថា រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន បានចូលរួមក្នុងសន្និសីទនេះ។ សមាសភាពប្រតិភូរួមមានតំណាងមកពីគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ក្រុមអ្នកបច្ចេកទេសប្រែប្រួលអាកាសធាតុ (CCTT) និងតំណាងនានាមកពីក្រសួងពាក់ព័ន្ធសំខាន់ៗ និងអង្គការសង្គមស៊ីវិល។

នៅមុនសន្និសីទនេះ កម្ពុជាបានដាក់ជូនឯកសារគោលជំហររបស់ខ្លួនទៅ UNFCCC ដោយប្រកាសថា កម្ពុជាគាំទ្រយ៉ាងពេញទំហឹងដល់កិច្ចប្រឹងប្រែងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ផ្អែកលើគោលការណ៍សំខាន់ៗរបស់ UNFCCC។ ដូចគ្នានេះដែរ គោលជំហរចរចាដែលកម្ពុជាបានស្នើឡើងគឺ ស្របគ្នាជាមួយនឹងគោលជំហររបស់បណ្តាប្រទេសអភិវឌ្ឍតិចតួច (LDCs) និងបណ្តាប្រទេស G77 បូកចិន។ ខាងក្រោមនេះជាចំណុចសំខាន់ៗដកស្រង់ចេញពីឯកសារគោលជំហរនេះ៖

គោលជំហររបស់កម្ពុជា៖

- ទទួលស្គាល់ថា ការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ការកាត់បន្ថយភាពក្រីក្រ គឺជាអាទិភាពចម្បងរបស់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។
- គាំទ្រផ្តល់អាទិភាពស្មើគ្នាលើការប្តេជ្ញាចិត្តក្នុងការអនុវត្តសកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់កិច្ចព្រមព្រៀងអាកាសធាតុនាពេលអនាគត។
- គាំទ្រឲ្យមានកិច្ចព្រមព្រៀងដំណាក់កាលទីពីរនៃពិធីសារក្យូតូ តែត្រូវរិះរកវិធីសាស្ត្រ ដើម្បីធ្វើឲ្យងាយជាងមុននូវនីតិវិធីអនុវត្តគម្រោង យន្តការអភិវឌ្ឍន៍ស្អាត (CDM) ដើម្បីអាចឲ្យប្រទេសអភិវឌ្ឍតិចតួច ចូលរួមអនុវត្តបានដោយពេញលេញ រួមទាំងគាំទ្រចំពោះយន្តការទីផ្សារកាបោនថ្មីៗបន្ថែមទៀត ដែលស្ថិតនៅក្រោមអនុសញ្ញា UNFCCC ។
- ជំរុញឲ្យប្រទេសអភិវឌ្ឍន៍បង្កើនការប្តេជ្ញាចិត្ត ក្នុងការផ្តល់ហិរញ្ញប្បទានបន្ថែមទៀតដល់ប្រទេសដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច។
- ជំរុញឲ្យបណ្តាប្រទេសអភិវឌ្ឍន៍ផ្តល់ហិរញ្ញប្បទានដល់ប្រទេសកំពុងអភិវឌ្ឍន៍ប្រចាំឆ្នាំឲ្យបាន ១០០ពាន់លានដុល្លារអាមេរិក ត្រឹមឆ្នាំ២០២០ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងកូប៉េនហាក។
- ស្វាគមន៍ការបង្កើតយន្តការបច្ចេកវិទ្យាអន្តរជាតិកាន់តុន ដែលប្រតិបត្តិការក្រោមសមត្ថកិច្ចនៃអនុសញ្ញា និងបណ្តាញការងារ UNFCCC ។
- គាំទ្រការបង្កើតគណៈកម្មាធិការប្រតិបត្តិផ្នែកបច្ចេកវិទ្យា (TEC) និងមជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុ (CTCN) ។
- ការកសាងសមត្ថភាពគួរជួយដល់ភាគីជាប្រទេសកំពុងអភិវឌ្ឍក្នុងការបង្កើត និងអនុវត្តគម្រោងកសាងសមត្ថភាព និងពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

សេចក្តីសម្រេចសំខាន់ៗរបស់សន្និសីទ CoP18 ៖

- សមាជិកទាំងអស់ឯកភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដល់កម្រិតអប្បបរមា ដើម្បីរក្សាកម្រិតនៃកំណើនសីតុណ្ហភាពមិនឲ្យលើសពី ២ អង្សាសែលស៊ីស។
- សម្រេចបន្តពិធីសារក្យូតូដំណាក់កាលទីពីរ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ដោយស្នើឲ្យបណ្តាប្រទេសឧស្សាហកម្មត្រូវកំណត់គោលដៅសេដ្ឋកិច្ចរបស់ខ្លួនក្នុងការកំណត់បរិមាណការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដើម្បីដាក់ជូនអង្គសន្និសីទពិនិត្យឡើងវិញត្រឹមឆ្នាំ ២០១៤ ក្នុងគោលបំណងបង្កើនកម្រិតប្តេជ្ញាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- សម្រេចព្រាងផែនការយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងការបាត់បង់ និងការខូចខាតបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងកសាងសមត្ថភាពរបស់ប្រទេសទាំងនោះក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។
- ឯកភាពលើការបង្កើតផែនការជាតិសម្រាប់ការបន្សាំ និងចាប់អនុវត្តការផ្តល់ជំនួយពីមូលនិធិ LDC ។
- សន្និសីទ CoP19 នឹងត្រូវរៀបចំធ្វើនៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ នៅចុងឆ្នាំ ២០១៣។

ឯកឧត្តម ធឹក គ្រឿនវុត្ថា រដ្ឋលេខាធិការ ក្រសួងបរិស្ថាន- ខាងស្តាំ, ឯកឧត្តម នុត ច័ន្ទសុធា សមាជិក NCCC មកពីក្រសួងផែនការ - កណ្តាល, លោកជំទាវ ប្រាក់ ចាន់ណាយ សមាជិក NCCC មកពីក្រសួងកិច្ចការនារី - ខាងឆ្វេង នៅក្នុងសន្និសីទ CoP

ប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចពិភាក្សានៅក្នុងសន្និសីទ CoP លើកទី១៨ ស្តីពីការអភិវឌ្ឍបៃតង និងយន្តការហិរញ្ញវត្ថុអាកាសធាតុ

Cambodia Climate Change Alliance (CCCA)
Implemented by / Supported by: Ministry of Environment, European Union, UNDP, Danida, SWEDEN

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា គឺជាកម្មវិធីទូលំទូលាយបែបច្នៃប្រឌិតថ្មីមួយ សម្រាប់ឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ កម្មវិធីនេះជាកិច្ចផ្តួចផ្តើមពហុភាគីដែលទទួលមូលនិធិពីសហភាពអឺរ៉ុប(EU), ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ(Sida) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (Danida) និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP) ។

បង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមអ្នកសារព័ត៌មានកម្ពុជា

ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ថ្លែងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាលជំនាញសារព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុនៅក្រសួងព័ត៌មាន។ រូបថតដោយ CCPDK/2013

នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣ ក្រសួងព័ត៌មាន បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញសារព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមកិច្ចសហការជាមួយក្រសួងបរិស្ថាន និងក្រោមការឧបត្ថម្ភ CCCA ។ ពិធីបើកវគ្គនេះមានការចូលរួមយ៉ាងកុះករពីសិក្ខាកាមប្រមាណ ១២០នាក់ ដែលរួមមានតំណាងពីស្ថាប័នរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល,គ្រឹះស្ថានសិក្សា និងស្ថាប័នផ្សព្វផ្សាយព័ត៌មាន។ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោកជំទាវ Anne Hoglund ឯកអគ្គរដ្ឋទូតស៊ុយអែដប្រចាំនៅកម្ពុជាបានចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះ។

វគ្គបណ្តុះបណ្តាលនេះមានគោលដៅបង្កើនការយល់ដឹងក្នុងចំណោមអ្នកសារព័ត៌មានកម្ពុជាអំពីការប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងការយល់ដឹងអំពីពាក្យបច្ចេកទេសប្រែប្រួលអាកាសធាតុ មូលហេតុ ឥទ្ធិពល និងយន្តការសំខាន់ៗ

តទៅទំព័រទី២

ដៃគូអភិវឌ្ឍន៍វាយតម្លៃខ្ពស់ចំពោះកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)

នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រសួងបរិស្ថានបានរៀបចំកិច្ចប្រជុំលើកទី៧ នៃក្រុមប្រឹក្សាភិបាល កម្មវិធី CCCA ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាភិបាលកម្មវិធី CCCA។

កិច្ចប្រជុំនេះមានការចូលរួមពីតំណាងដៃគូអភិវឌ្ឍន៍របស់ CCCA រួមមាន សហភាពអឺរ៉ុប ស្ថានទូតស៊ុយអែដ និង UNDP ។ គោលបំណងចំបងនៃកិច្ចប្រជុំនេះគឺ ពិនិត្យមើលការអនុវត្តកម្មវិធី CCCA ក្នុងឆ្នាំ២០១២ លើកផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៣-២០១៤ និងពិភាក្សាអំពីការវិវឌ្ឍន៍នៃក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា ដែលជាយន្តការមានប្រសិទ្ធិភាពក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ។ ក្នុងសុន្ទរកថាស្វាគមន៍ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត បានគូសបញ្ជាក់អំពីសមិទ្ធិផលសំខាន់ៗរបស់កម្មវិធី CCCA រួមមានការបង្កើតក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជាការផ្តល់ប្រាក់ជំនួយដល់គម្រោងសាកល្បងស្តីពីការប្រែប្រួលអាកាសធាតុចំនួន ១៩ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុការបញ្ជ្រាបការអប់រំ និងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និង

តទៅទំព័រទី២

ព្រឹត្តិបត្រព័ត៌មាន
ប្រចាំត្រីមាសទី១ ឆ្នាំ ២០១៣
លេខ ១

មាតិកា

បច្ចេកវិទ្យាបន្សាំក្នុងវិស័យកសិកម្ម ត្រូវបានសាកល្បងនៅខេត្តព្រៃវែង	៣
CCCSP នឹងជួយប្រជាជនកម្ពុជានៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ	៤
ពង្រឹងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមយុវជនតាមរយៈបណ្ណាល័យប្រែប្រួលអាកាសធាតុ	៤
ឡជីវឧស្ម័នធ្វើអោយជីវភាពប្រជាជននៅខេត្តស្វាយរៀងប្រសើរឡើង	៥
ជំហររបស់កម្ពុជានៅក្នុង COP18, និងការឆ្លើយតបជាអន្តរជាតិ	៦

បង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ...

គំនិតជាមូលដ្ឋានស្តីពីហេតុផល និងយន្តការជាគន្លឹះសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនសុក្រឹតភាព និងវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធផ្សព្វផ្សាយលើការប្រែប្រួលអាកាសធាតុ។

ការសិក្សាថ្មីមួយរបស់ក្រសួងបរិស្ថានបានបង្ហាញថា ការយល់ដឹងរបស់សាធារណជនកម្ពុជាអំពីការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ ដែលនេះគឺជាឧបសគ្គដ៏ធំមួយ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា ក៏ដូចជាក្នុងការជួយកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន។ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត មានប្រសាសន៍ក្នុងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាលជំនាញសារព័ត៌មានថា "ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមសាធារណជនកម្ពុជានៅមានកម្រិតនៅឡើយ ដែលនេះជាការប្រឈមដ៏ធំមួយក្នុងការទាក់ទាញសាធារណជនឲ្យចូលរួមរបស់ប្រជាជន ក្នុងសកម្មភាពឆ្លើយតបប្រកបដោយប្រសិទ្ធិភាពទៅនឹងការប្រែប្រួលអាកាសធាតុ" ។

អ្នកជំនាញការក្នុងវិស័យប្រែប្រួលអាកាសធាតុបានទទួលការអញ្ជើញចូលរួមចែករំលែកចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ

របកគំហើញពីការសិក្សានេះបានរួមចំណែកធ្វើឲ្យក្រសួងព័ត៌មានដើរតួនាទីមួយយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុឲ្យបានទូលំទូលាយ ដោយសារប្រជាជនកម្ពុជាភាគច្រើន ជាពិសេសប្រជាជននៅតាមសហគមន៍ជនបទពឹងផ្អែកលើប្រព័ន្ធផ្សព្វផ្សាយ ដើម្បីទទួលព័ត៌មាន។

វគ្គបណ្តុះបណ្តាលដែលមានរយៈពេលពីរថ្ងៃនេះ បានផ្តល់ចំណេះដឹងអំពីមូលហេតុ ហានិភ័យ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើវិស័យសំខាន់ៗ និងយុទ្ធសាស្ត្រឆ្លើយតបផ្សេងៗ។ ក្រោយទទួលការបណ្តុះបណ្តាលអំពីទ្រឹស្តី សិក្ខាកាមត្រូវបានចាត់តាំងឲ្យចុះធ្វើការនៅតាមមូលដ្ឋានរយៈពេលបីខែ ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ សម្រាប់អត្ថបទរបស់ពួកគេ ដោយមានអ្នកជំនាញការខាងសារព័ត៌មានជាអ្នកផ្តល់ការណែនាំបន្ថែម។ ឯកឧត្តម ខៀវ កញ្ញារិទ្ធ បានមានប្រសាសន៍ថា អ្នកសារព័ត៌មាននឹងអាចសរសេរអត្ថបទអំពីការប្រែប្រួលអាកាសធាតុកាន់តែសុក្រឹតជាងមុន ក្រោយពីបានទទួលការបណ្តុះបណ្តាលនេះ។

ដៃគូអភិវឌ្ឍន៍ CCCA ...

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៧ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងការអនុវត្តសមាសភាគបន្សុំានៅតំបន់ឆ្នេរ។

ដៃគូអភិវឌ្ឍន៍របស់ CCCA បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលរបស់ CCCA ក្រោមការចាត់ចែង និងសម្របសម្រួលរបស់ក្រសួងបរិស្ថាន ហើយបានផ្តល់អនុសាសន៍ស្ថាបនាបន្ថែមលើសកម្មភាពសំខាន់ៗ រួមមាន ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងការរៀបចំបង្កើតក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា។ កិច្ចពិភាក្សាក៏បានផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការ និងការកៀរគរធនធានសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុទៅអនាគត ដែលជួយជម្រុញឲ្យកម្ពុជាអភិវឌ្ឍទៅរកសង្គមមួយដែលកាន់តែបៃតង ធន់នឹងការប្រែប្រួលអាកាសធាតុ ប្រកបដោយសមធម៌ ចីរភាព និងជាសង្គមមួយដែលអភិវឌ្ឍផ្អែកលើមូលដ្ឋានចំណេះវិជ្ជា ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រីតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងវេទិកាជាតិលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ។

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលជាកិច្ចផ្តួចផ្តើមពហុម្ចាស់ជំនួយទទួលមូលនិធិពីសហភាពអឺរ៉ុប ស្ថានទូតស៊ុយអែដ UNDP និងDanida ត្រូវបានចាប់ផ្តើមក្នុងឆ្នាំ ២០១០ ដោយមានប្រាក់ជំនួយសរុប ១២ លានដុល្លារអាមេរិក។ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន គឺជាស្ថាប័នសម្របសម្រួលកម្មវិធីនេះ ក្នុងគោលបំណងពង្រឹងស្ថាប័នរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលស្របតាមអាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។

បច្ចេកវិទ្យាបន្សុំាក្នុងវិស័យកសិកម្មត្រូវបានសាកល្បងនៅខេត្តព្រៃវែង

ការណែនាំឲ្យប្រើប្រាស់បច្ចេកវិទ្យាកសិកម្មប្រកបដោយប្រសិទ្ធិភាព និងពូជស្រូវសមស្រប អាចជួយប្រជាជនបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ គម្រោងជំនួយមួយរបស់ CCCA កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាកសិករដើម្បីសាកល្បងវិធីសាស្ត្រនេះ នៅខេត្តព្រៃវែង ដែលត្រូវបានស្គាល់ថា ជាខេត្តងាយរងគ្រោះនឹងផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុ ដូចជា គ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង និងទឹកជំនន់ធ្ងន់ធ្ងរ។

គម្រោង"បង្កើត-ដាំដុះ-បន្សុំា" (BUILD-FARM-ADAPT) ដែលអនុវត្តដោយសកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រោមកិច្ចសហការជាមួយសកលវិទ្យាល័យ ជា ស៊ីមកំចាយមា កំពុងសាកល្បងវិធីសាស្ត្របន្សុំាក្នុងស្រុកចំនួនបីនៃខេត្តព្រៃវែង គឺ ស្រុកបាភ្នំ ស្រុកកំចាយមា និងស្រុកពារាំង។ ពូជស្រូវពីរប្រភេទ គឺ ផលសារ និងរាំងជ័យ និងបច្ចេកវិទ្យាបង្កើនផលិតផលកសិកម្ម ត្រូវបានដាក់ឲ្យកសិករប្រើប្រាស់ ដើម្បីបង្កើនទិន្នផល កាត់បន្ថយសត្វចង្រៃ និងការប្រើប្រាស់ជីគីមី។

អ្នកទទួលផលពី CCCA សប្បាយរីករាយ ដែលបានឃើញទិន្នផលខ្ពស់ជាងការរំពឹងទុក ហើយបានថ្លែងអំណរគុណដល់ CCCA និងម្ចាស់ជំនួយនៃកម្មវិធីនេះ

ផលសារ និងរាំងជ័យ ស្ថិតក្នុងចំណោមពូជស្រូវជម្រើសចំនួន ១០ ប្រភេទរបស់រាជរដ្ឋាភិបាល។ ពូជស្រូវទាំងពីរត្រូវបានណែនាំឲ្យប្រើសម្រាប់តំបន់ដែលងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត។ ផលសារ ជាប្រភេទពូជស្រូវស្រាល ដែលអាចប្រមូលផលក្នុងរយៈពេលតិចជាង ៩០ថ្ងៃ ហើយកសិករអាចដាំនៅមុន និងក្រោយទឹកជំនន់។ រាំងជ័យ ជាប្រភេទពូជស្រូវធ្ងន់ ដែលធន់នឹងគ្រោះរាំងស្ងួតរយៈពេលវែង ដូច្នេះ វាសមស្របសម្រាប់តំបន់ដែលងាយរងគ្រោះដោយសារគ្រោះរាំងស្ងួត។ ស្រូវប្រភេទនេះក៏អាចធន់ទ្រាំនឹងការជន់លិច បានរយៈពេល ៧ ថ្ងៃ។

កសិករម្នាក់លើកបង្ហាញស្រូវផលសារ ក្រោយការប្រមូលផលដំបូងរបស់គាត់

ក្នុងខែមករា ឆ្នាំ២០១៣ ម្ចាស់ជំនួយរបស់ CCCA បានធ្វើទស្សនកិច្ចនៅទីតាំងអនុវត្តសាកល្បងចំនួនបី និងបានសំដែងការពេញចិត្តចំពោះលទ្ធផលវិជ្ជមាននេះ។ លោក តឿន អេរ៉ើត តំណាងប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា *"វាគួរឲ្យចាប់អារម្មណ៍ណាស់នៅពេលដែលឃើញកសិករមានចំណាប់អារម្មណ៍វិជ្ជមានចំពោះពូជស្រូវ និងបច្ចេកទេសថ្មីទាំងនេះ។ តាមធម្មតា កសិករស្ទាក់ស្ទើរ មិនចង់ប្តូរពូជស្រូវដែលពួកគេធ្លាប់ប្រើពីមុនមកភ្លាមៗនោះទេ ប៉ុន្តែពូជស្រូវទាំងនេះប្រាកដជាបានទាក់ទាញចំណាប់អារម្មណ៍របស់ពួកគេហើយ"។*

អ្នកទទួលផលពីកម្មវិធី CCCA នៅទីតាំងអនុវត្តសាកល្បងក្នុងស្រុកពារាំង ខេត្តព្រៃវែង បាននិយាយថា *"ខ្ញុំសូមថ្លែងអំណរគុណចំពោះកម្មវិធី CCCA ដែលបានណែនាំឲ្យមានការប្រើស្រូវពូជផលសារ នៅភូមិរបស់ខ្ញុំ និងបានជួយផ្តល់បច្ចេកទេសកសិកម្មដល់យើង។ ឥឡូវនេះ យើងអាចទទួលទិន្នផលខ្ពស់ជាងមុន ដោយប្រើជីតិចជាងមុន ហើយអាចប្រមូលផលនៅមុនទឹកជំនន់មកដល់។ ខ្ញុំចង់ឲ្យ CCCA ផ្សព្វផ្សាយពូជនេះដល់អ្នកដទៃទៀតនៅក្នុងភូមិ "។*

អ្នកភូមិដែលរស់នៅក្បែរអ្នកទទួលផលពីកម្មវិធីនេះ ក៏ចាប់អារម្មណ៍លើពូជស្រូវទាំងនេះដែរ និងបានស្នើឲ្យមានការផ្តល់ពូជ និងបច្ចេកវិទ្យាបន្ថែមទៅអ្នកដទៃទៀតនៅក្នុងភូមិ។ គម្រោងនេះផ្ទាល់បានផ្តួចផ្តើមរួចមកហើយនូវមធ្យោបាយចែករំលែករយៈពេលវែង ដោយឲ្យអ្នកទទួលផលចែករំលែកខ្លះៗនូវផលដែលប្រមូលបានដំបូង ដល់អ្នកជិតខាង។

ទោះបីជាយ៉ាងណាក៏ដោយ ឧបសគ្គមួយដែលអ្នកទទួលផលបានប្រឈមនោះគឺ យន្តការទីផ្សារនៅពុំទាន់ដំណើរការបានពេញលេញដើម្បីគាំពារដល់ប្រភេទស្រូវថ្មីទាំងនេះនៅឡើយ (ឧទាហរណ៍៖ ត្រូវផលិតពូជឲ្យបានច្រើន

ស្រែបង្ហាញពូជស្រូវរាំងជ័យ ក្នុងស្រុកពារាំង ខេត្តព្រៃវែង

CCCSP នឹងរួមចំណែកជួយប្រជាជនកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជាបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការឆ្លើយតបប្រកបដោយប្រសិទ្ធិភាព ទៅនឹងការប្រែប្រួលអាកាសធាតុ ដោយសារកម្ពុជាកន្លងមកធ្លាប់បានជួបប្រទះការខូចខាត ដែលបណ្តាលមកពីគ្រោះមហន្តរាយអាកាសធាតុ មកលើសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋ ហេតុនេះហើយទើបជំរុញឲ្យមានការរៀបចំផែនការយុទ្ធសាស្ត្រជាតិប្រែប្រួលអាកាសធាតុ ដើម្បីបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។

ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ (CCCA) នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន កំពុងដឹកនាំការរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ទន្ទឹមនឹងការគាំទ្រដល់ក្រសួងពាក់ព័ន្ធចំនួនប្រាំបួន ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរៀងៗខ្លួន (CCSP តាមវិស័យ) ដែលជាមូលដ្ឋានសម្រាប់ការអនុវត្ត CCCSP។ ការរៀបចំ CCCSP និង CCSP តាមវិស័យ មានគោលដៅរក្សាការពារជីវភាពរបស់ប្រជាជនកម្ពុជា សេដ្ឋកិច្ច និងធម្មជាតិ ពីឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ក៏ដូចជា គាំទ្រដល់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ជាតិផងដែរ។

កិច្ចការក្នុងឆ្នាំ ២០១២ ផ្តោតការយកចិត្តទុកដាក់លើការរៀបចំ និងការបន្សុីគ្នារវាង CCCSP និង CCSP តាមវិស័យ។ នៅចុងឆ្នាំ ២០១២ សេចក្តីព្រាងលើកទីមួយ CCCSP និង CCSP តាមវិស័យ របស់ក្រសួងពាក់ព័ន្ធចំនួនប្រាំបួន ត្រូវបានរៀបចំរួចរាល់ជាស្ថាពរ។

បច្ចុប្បន្ននេះ CCCSP កំពុងស្ថិតក្នុងដំណាក់កាលពិនិត្យ និងពិគ្រោះយោបល់បច្ចេកទេសជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដែលរួមមានសង្គមស៊ីវិល

តំណាងពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់អំពី CCCSP

វិស័យឯកជន ស្ថាប័នអប់រំ និងស្ថាប័នស្រាវជ្រាវនានា។ កិច្ចប្រជុំពិគ្រោះយោបល់កន្លងមកបានទទួលមតិយោបល់ជាច្រើនពីភាគីពាក់ព័ន្ធដែលមានបទពិសោធន៍លើការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា។ មជ្ឈដ្ឋានខាងក្រៅមានចំណាប់អារម្មណ៍ខ្លាំង ជាពិសេសអង្គការសង្គមស៊ីវិល និងវិស័យឯកជន ដែលចង់ឃើញផែនការសកម្មភាពរបស់ CCCSP និង CCSP តាមវិស័យ លេចជារូបរាងឡើង។ ក្រុមការងារ CCCSP នឹងចាត់ចែងកិច្ចពិគ្រោះយោបល់បន្ថែមទៀតជាមួយដៃគូអភិវឌ្ឍន៍របស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងក្រសួង ពាក់ព័ន្ធទាំងប្រាំបួន។ បន្ទាប់មក ក្រុមការងារនឹងប្រមូលសរុបមតិយោបល់ទាំងនោះ មុននឹងរៀបចំកិច្ចពិគ្រោះយោបល់ចុងក្រោយ ។ នៅដំណាក់កាលចុងក្រោយ CCCSP នឹងត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត និងប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ពង្រឹងចំណេះដឹងក្នុងចំណោមយុវជនអំពីការប្រែប្រួលអាកាសធាតុតាមរយៈបណ្ណាល័យប្រែប្រួលអាកាសធាតុ

ពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់ស្តីពីការបង្កើតកន្លែងផ្ទុកឯកសារក្នុងបណ្ណាល័យជាមួយសកលវិទ្យាល័យភូមិន្ទកសិកម្ម

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាសាំញ៉ាំ ដែលបង្កការប្រឈមមកលើគ្រប់វិស័យទាំងអស់ ហើយទាមទារឲ្យមានការពង្រីកនូវការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ដើម្បីទទួលបានព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ សម្រាប់ជួយប្រជាជនបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ ដើម្បីជំរុញការស្រាវជ្រាវ ទាមទារឲ្យមានធនធានមនុស្ស អាកាសធាតុឲ្យបានកាន់តែច្រើន។ ដូចនេះយើងត្រូវពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ចាប់ពីកម្រិតមធ្យមសិក្សារហូតដល់ឧត្តមសិក្សា។

បច្ចុប្បន្ន CCCA កំពុងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ សំដៅបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងវិស័យអប់រំ។ លើសពីនេះ CCCA បានសហការជាមួយសកលវិទ្យាល័យចំនួនបី គឺ សកលវិទ្យាល័យភូមិន្ទភ្នំពេញ សកលវិទ្យាល័យភូមិន្ទកសិកម្ម និងសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដើម្បីបង្កើតផ្នែកការប្រែប្រួលអាកាសធាតុក្នុងបណ្ណាល័យនៃសកលវិទ្យាល័យទាំងនោះ ក្នុងបំណងបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងជម្រុញការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមនិស្សិតសកលវិទ្យាល័យ និងអ្នកស្រាវជ្រាវ។

CCCA នឹងបន្តផ្តល់សៀវភៅ និងឯកសារទាក់ទងនឹងការប្រែប្រួលអាកាសធាតុដល់បណ្ណាល័យទាំងនេះ ហើយនឹងលើកទឹកចិត្តភាគីពាក់ព័ន្ធទាំងអស់ឲ្យផ្តល់ឯកសារបន្ថែមទាក់ទងនឹងការប្រែប្រួលអាកាសធាតុដល់បណ្ណាល័យទាំងនេះ ដើម្បីពង្រីកឃ្លាំងចំណេះដឹងប្រែប្រួលអាកាសធាតុ។